# ប្រទេសកម្ពុជា:
# ក្រុមអង្គការអន្តរជាតិថ្កោលទោសចំពោះការកាត់ទោសបុគ្គលិកសិទ្ធិមនុស្សក្នុងស្រុក
# ការចាប់ខ្លួនតាមតែទំនើងចិត្ត ការកាត់ក្តីមិនយុត្តិធម៌គួសសំគាល់
# ដោយនីតិវិធីមិនប្រក្រតី

ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០

អង្គការសិទ្ធិមនុស្សអន្តរជាតិចំនួន៤ បានជំរុញឲ្យរដ្ឋាភិបាលកម្ពុជាដោះលែងលោក លាង សុខជឿន ជាបន្ទាន់ ដែលលោកជាបុគ្គលិករបស់សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ដែលត្រូវបានកាត់ឲ្យជាប់ពន្ធនាគារពីបទផ្សាយព័ត៌មានមិនពិតនៅថ្ងៃទី៣០ ខែសីហា។

នៅក្នុងសេចក្តីថ្លែងការណ៍រួមថ្ងៃនេះ អង្គការលើកលែងទោសអន្តរជាតិ អង្គការឃ្លាំមើលសិទ្ធិមនុស្ស សហព័ន្ធអន្តរជាតិសិទ្ធិមនុស្ស (FIDH) និងអង្គការប្រឆាំងអំពើទារុណកម្មពិភពលោក (OMCT) សម្តែងការសោកស្តាយចំពោះការឃុំខ្លួនលោក សុខជឿន ។ ការកាត់ក្តីលោក សុខជឿន កាលពីថ្ងៃទី៣០ ខែសីហា គួសសំគាល់ពីគុណវិបត្តិនីតិវិធីជាច្រើន ព្រមទាំងការរំលោភបំពានចំពោះការផ្តល់ការកាត់ក្តីដោយយុត្តិធម៌នៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។

"ការកាត់ទោសឲ្យជាប់ពន្ធនាគារនេះ ធ្វើឲ្យលេចឡើងនូវការខ្វះខាតពីភាពឯករាជ្យ និងភាពមិនលំអៀងរបស់តុលាការ ដែលជារឿយៗត្រូវបានប្រើជាមធ្យោបាយប្រឆាំងជាមួយនឹងអ្នកមានអំណាចតិចតួច ជាជាងការការពារសិទ្ធិរបស់អ្នកទាំងនោះ" នេះគឺជាប្រសាសន៍របស់លោកស្រី ដូណា ហ្គេស នាយករងប្រចាំអាស៊ីប៉ាស៊ីហ្វិចនៃអង្គការលើកលែងទោសអន្តរជាតិ។

នគរបាលកម្ពុជា បានចាប់ខ្លួនលោក សុខជឿន កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១០ ក្រោមបទចោទប្រកាន់ថា មានជាប់ពាក់ព័ន្ធនឹងការផលិត និងចែកចាយខិត្តប័ណ្ណ (ត្រាក់) ប្រឆាំងនឹងរដ្ឋាភិបាលនៅខេត្តតាកែវ កាលពីខែមករា។ លោក សុខជឿន ត្រូវបានឃាត់ទុកដោយផ្តាច់ការទំនាក់ទំនងអស់រយៈពេលជាង ៣៣ម៉ោង ទោះបីជាមានសំណូមពរជាច្រើនលើកពីក្រុមគ្រួសាររបស់លោក និងមេធាវីដើម្បីសួរសុខទុក្ខលោកយ៉ាងណាក៏ដោយ។ សវនាការ កាលពីថ្ងៃទី៣០ សីហា លោក សុខជឿន ត្រូវបានកាត់ឲ្យជាប់ពន្ធនាគារ ២ឆ្នាំ ពិន័យជាប្រាក់ ២លានរៀល (៥០០ ដុល្លារសហរដ្ឋអាមេរិក) ពីបទផ្សាយព័ត៌មានមិនពិត។

"ការចោទប្រកាន់ ដោយគ្មានមូលដ្ឋានច្បាស់លាស់ពីបទផ្សាយព័ត៌មានមិនពិត ឬបទបរិហារកេរ្តិ៍ គឺជាមធ្យោបាយដែលប្រើហើយប្រើទៀត ដោយរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើតបរិយាកាសភ័យខ្លាច" នេះជាសំដីរបស់លោក ហ្វិល រ៉ូប៊ីតសុន នាយករងប្រចាំអាស៊ីនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស ។

លោកស្រី ស៊ូហាយ ប៉េលហាសិន ប្រធានសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិមានប្រសាសន៍ ថា "យើងអះអាងការអំពាវនាវរបស់យើងជាថ្មី ចំពោះអាជ្ញាធរកម្ពុជាឲ្យលុបបំបាត់អំពើឧក្រិដ្ឋនៃបទបរិហាកេរ្តិ៍ និងបទផ្សាយព័ត៌មានមិនពិតនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ហើយធានាថា ក្រមព្រហ្មទណ្ឌមិនត្រូវបានប្រើដើម្បីរឹតបន្តឹងដោយរំលោភបំពានទៅនឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ" ។

លោក អ៊ីរិក សូតាស អគ្គលេខាធិការប្រចាំអង្គការប្រឆាំងអំពើទារុណកម្មពិភពលោកបានបន្ថែមទៀតថា "លោក លៀង សុខជឿន គួរតែត្រូវបានដោះលែងជាបន្ទាន់ ហើយមិនមានល័ក្ខខ័ណ្ឌ ដោយសារតែការឃុំខ្លួននេះ គឺជាការឃុំខ្លួនតាមតែទំនើងចិត្ត ហើយនីតិវិធីត្រឹមត្រូវត្រូវបានរំលោភបំពានដោយឃើញច្បាស់លាស់ទាំងដំណាក់កាលស៊ើបអង្កេត និងសវនាការ" ។

**សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

- សហព័ន្ធសិទ្ធិ មនុស្សអន្តរជាតិ ៖ លោក ហ្សាបៀន ម៉េត្រេ<br>ទូរស័ព្ទលេខ +៣៣-១ ៤៣ ៥៥ ២៥ ១៨
- អង្គការប្រឆាំងអំពើទារុណកម្មពិភពលោក៖ លោក អ៊ីរិក សូតាស<br>ទូរស័ព្ទលេខ +៤១-២២ ៨០៩ ៤៩ ៣៩
- អង្គការឃ្លាំមើលសិទ្ធិមនុស្ស ៖ លោក ហ្វិល រ៉ូប៊ឺតសុន<br>ទូរស័ព្ទលេខ + ៦៦-៨៥ ០៦០ ៨៤០៦ (ទីក្រុងបាងកក)
- អង្គការឃ្លាំមើលសិទ្ធិមនុស្ស៖ លោកស្រី សុហ្វី រីឆាតសុន +១-២០ ២៦១២ ៤៣៨១ (ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី)
- អង្គការលើកលែងទោសអន្តរជាតិ៖ + ៤៤-២០ ៧៤១៣ ៥៥៦៦